## មន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ
## ខេត្តពោធិ៍សាត់

# ផលិតកម្មគ្រាប់ពូជស្រូវសុទ្ធ




រៀបរៀងដោយ លោកស្រី យឹម សុភី

អនុប្រធាន ការិយាល័យក្សេត្រសាស្ត្រ និងផលិតភាពកសិកម្ម


ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៧


Email: ysophy168@gmail.com and 012 558 312

- ដំណើរការផលិតកម្មគ្រាប់ពូជស្រូវ



# គោលបំណង

១.អោយកសិករចេះផលិតកម្មគ្រាប់ពូជស្រូវសុទ្ធដោយស្លួនឯង
២.អោយកសិករទទួលបាននៅពូជស្រូវសុទ្ធល្អសម្រាប់ប្រើប្រាស់







# គុណវិបត្តិនៃការប្រើប្រាស់ពូជមិនសុទ្ធ



1- មិនអាចទុកពូជសម្រាប់ធ្វើបន្តបាន

2- បាត់បង់ពី ១០-៣០%

3- អង្ករ ឬស្រូវ លក់បានតម្លៃថោក

4- ពេលកិនអង្ករបាក់ច្រើន

5- បាយទន់ទៅជារឹង បាត់ក្លិនក្រអូប

6- បាយឆ្អិនមិនស្មើ និងឆាប់ផ្អូម



# ការជ្រើសរើសទីកន្លែងធ្វើថ្នាលសំណាប

- ជ្រើសរើសស្រែដែលរាបស្មើ និងមានជីជាតិ។
- មិនត្រូវជ្រើសរើសស្រែដែលនៅក្រោមម្លប់ ពីព្រោះវាជម្រុញឱ្យមានការបំផ្លាញពីជម្ងឺ និងសត្វល្អិត។
- ស្រែជ្រើសរើសសម្រាប់ធ្វើថ្នាលសំណាបគួរតែនៅជិតប្រភពទឹក ប៉ុន្តែមិនមែនជាកន្លែងដែលអាចទទួលការជន់លិចនៃទឹកឡើយ។
- ថ្នាលដែលជ្រើសរើសសម្រាប់ជាថ្នាលសំណាប មិនត្រូវអោយមានសំណាប



# ការជ្រើសរើសទីកន្លែងធ្វើថ្នាលសំណាប...ត
...

- ថ្នាលសំណាបដែលត្រូវជ្រើសរើសដាំពូជផ្សេងៗគ្នា ត្រូវមានចម្ងាយនៅឆ្ងាយពីគ្នា ៥-១០ម។
- ស្រែទាំងនោះគួរខ័ណ្ឌចែកគ្នាដោយភ្លឺ ដើម្បីការពារទប់ទល់ទៅនឹងការហូរលាយចូលគ្នារវាងពូជនីមួយៗ ក្នុងពេលបញ្ចេញបញ្ចូលទឹកក្រោយសាប។
- ថ្នាលសំណាបនៃពូជពីរ ឬច្រើន នៅក្នុងស្រែដែលជាប់គ្នា ក៏ប្រហែលត្រូវបានសាបក្នុងពេលខុសគ្នា ដើម្បីពិនិត្យការលាយ។

# ការរៀបចំដី និងការថែទាំថ្នាលសំណាប

- ធ្វើស្រែអោយស្អាតល្អមុនពេលសាប។ ភ្ជួរ ឬរាស់ស្រែ ២-៣ ដងហើយពង្រាបដីអោយស្មើល្អមានលក្ខណៈឯកសណ្ឋានភាព។
- រង់ចាំ ៧-១០ ថ្ងៃ ដើម្បីទុកអោយស្មៅ និងគ្រាប់ពូជផ្សេងៗ ទៀតដុះ។ ភ្ជួរ ឬរាស់ដីម្តងទៀត និងពង្រាងដីអោយស្មើ។
- ទុកដីអោយរង និងបន្ទាប់មកលើកថ្នាលទៅតាមទំហំដែលចង់ បាន។ ត្រូវបញ្ចេញទឹកដែលលើសចំណុះ

# ការរៀបចំដី និងការថែទាំថ្នាលសំណាប...ត...

- កុំសាបញឹកពេក។ ដើម្បីទទួលបាននូវសំណាបដែលមានសុខភាពល្អ ត្រូវសាបគ្រាប់ពូជ ១ គីឡូក្រាម/១០-១៥ម$^{២}$។
- បញ្ចូលទឹកថ្នាលសំណាបទៅតាមតម្រូវការវា។ ជៀសវាងកុំឱ្យហួសកំណត់រហូតដល់លិចសំណាប នាំឱ្យរលួយ។
- បាចជីអាសូត និងធាតុចិញ្ចឹមដទៃៗ ទៀតទៅតាមកម្រិតណែនាំ ប្រសិនបើបាចជីលាមកសត្វ ត្រូវប្រាកដ

# ការជ្រើសរើសដីស្រែ

- ជ្រើសរើសស្រែសម្រាប់ធ្វើផលិតកម្មពូជ នៅជិតប្រព័ន្ធស្រោចស្រព ដើម្បីងាយបញ្ចេញបញ្ចូលទឹកទៅតាមតម្រូវការលូតលាស់
- ស្រែគួរតែមានសភាពរាបស្មើល្អ និងត្រូវតែមានលក្ខណៈឯកសណ្ឋានភាពដី។
- ស្រែមិនគួរស្ថិតនៅកន្លែងណា ដែលធ្លាប់ទទួលរងនូវការជន់លិច ឬខ្វះទឹក ឬម្លប់។
- ស្រែដែលស្ទូងពូជខុសៗ គ្នា គួរតែឃ្លាតពីគ្នាចម្ងាយ ៣-៥ ម ដើម្បីជៀសវាងការក្លាយពីពូជមួយទៀត។

ត្រូវធ្វើថ្នាលនិងសាបសំណាបនៅជិតប្រភពទឹក



# ការរៀបចំស្រែ

- ជាការចាំបាច់ណាស់ ត្រូវរៀបចំស្រែអោយបានស្មើល្អ ដោយធ្វើការរៀបចំដី ២-៣ ដង ដើម្បីសម្រួលដល់ការដុះលូតលាស់របស់រុក្ខជាតិចង្រៃ និងកំចាត់វាជាមុនសិន។

# ការស្ទូងក្នុងស្រែ

- ត្រូវស្ទូងសំណាបដែលមានអាយុ ២០-២៥ ថ្ងៃ ចំពោះពូជស្រាល ៣០-៣៥ ថ្ងៃពូជកណ្តាល និងពូជធ្ងន់។
- ស្ទូងសំណាប ២-៣ ដើមក្នុងមួយគុម្ព ដែលគ្មានការខូចខាតឫស ដើម្បីប្រយ័ត្នកុំអោយមានការងាប់ច្រើន និងជៀសវាងកុំអោយមានការជួសសន្ទូង ដែលបង្កអោយមានភាពខុសគ្នានៅក្នុងការដាំដុះ លូតលាស់ ដែលដុះមិនស្មើគ្នា។






# ការថែទាំទឹក

- អនុលោមទៅតាមការថែទាំទឹកបានល្អ នោះជាកត្តាដែលមានសារៈសំខាន់ណាស់សម្រាប់ផលិតកម្មគ្រាប់ពូជបានល្អ។
- ភាពមានទឹកលើសលប់ហួសប្រមាណ ក្រោយពេលស្ទូងភ្លាមៗ ជាហេតុបង្កអោយសំណាបងាប់។
- ប្រសិនបើការបង្ហូរទឹកចេញអស់រលីង ហើយនឹងភាពរំខានផ្សេងៗ នឹងជម្រុញអោយមានការដុះលូតលាស់ស្មៅ និងពូជលាយ។

# ការបាចដីចំពោះប្រភេទស្រូវស្រាល

| ប្រភេទដី | ប្រភេទជី | ទ្រាប់បាត គក/ហាត | បំប៉ន គក/ហាត |
| --- | --- | --- | --- |
| ដីខ្សាច់ (ព្រៃខ្មែរ, ប្រទះឡាង) | អ៊ុយរ៉េ | ១៥-៣៥ | ២២-៥៤ |
| | ដេអាប៉េ | ១៧-៥០ | ០ |
| | ប៉ូតាស | ៥០-៦៧ | ០ |
| ដីល្បាយឥដ្ឋ (បាកាន, អូររាំង, ទួលសំរោង, គោកត្រប់, ក្រគរ) | អ៊ុយរ៉េ | ៩៩-១០១ | ៧១-១០៣ |
| | ដេអាប៉េ | ៥៤-៧៦ | ០ |
| | ប៉ូតាស | ០-៥០ | ០ |
| ដីឥដ្ឋ (កំពង់សៀម, ក្បាលពោធិ, កៀនស្វាយ) | អ៊ុយរ៉េ | ៣៩-១៥៧ | ៥៤-១៩៦ |
| | ដេអាប៉េ | ៣៩-៩៨ | ០ |
| | ប៉ូតាស | ០ | ០ |

# ការបាចជីចំពោះប្រភេទស្រូវកណ្តាល និងធ្ងន់

| ប្រភេទដី | ប្រភេទដី | ទ្រាប់បាត គក/ហាត | បំប៉នទី ១ គក/ហាត | បំប៉នទី ២ គក/ហាត |
|---|---|---|---|---|
| ដីខ្សាច់ (ព្រៃខ្មែរ, ប្រទះឡាង) | អ៊ុយរ៉េ | ១៦-៣១ | ៣៥-៨៧ | ២៦-៦៦ |
| | ដេអាប៉េ | ២៦-៨៧ | ០ | ០ |
| | ប៉ូតាស | ១០០-១៣៣ | ០ | ០ |
| ដីល្បាយឥដ្ឋ (បាកាន, អូររាំង, ទួលសំរោង, គោកត្រប់, ក្រគរ) | អ៊ុយរ៉េ | ២៧-៥២ | ១០៥ | ៦០-៧៩ |
| | ដេអាប៉េ | ៥៥-១៣០ | ០ | ០ |
| | ប៉ូតាស | ០-៦៧ | ០ | ០ |
| ដីឥដ្ឋ (កំពង់សៀម, ក្បាលពោធិ, កៀនស្វាយ) | អ៊ុយរ៉េ | ៥០-៥៣ | ៧០-៨៧ | ៥៣-៦៦ |
| | ដេអាប៉េ | ០-៣៩ | ០ | ០ |
| | ប៉ូតាស | ០ | ០ | ០ |


ការកាត់ពូជលាយចោល
សម្រាប់ផលិតកម្មគ្រាប់ពូជសុទ្ធ

# ប្រភពនៃពូជលាយ

- ការក្លាយនៃលក្ខណៈសេនេទិច
- ការដុះសារពីរដូវមុន
- ការដុះម្លូរ
- គ្រាប់ពូជដែលបានលាយមកជាមួយ

# ដំណាក់កាលនៃការកាត់ពូជលាយចោល

- ដំណាក់កាលស្រូវបែកគុម្ពខ្លាំ
- ដំណាក់កាលចេញផ្កា
- ដំណាក់កាលស្រូវទុំ



ការសំអាតស្មៅ និងការដកពូជស្រូវលាយចោល



# លក្ខណៈសំគាល់ដើម្បីសំគាល់ពូជលាយ

- ដំណាក់កាលស្រូវបែកគុម្ពខ្លាំង: កំពស់ êទាប, ខ្ពស់é ពណ៌ស្លឹក និងដើម, សណ្ឋានស្លឹក êទំហំ, ឈរត្រង់, ដេក, ធ្លាក់សំយ៉ុងé និងសណ្ឋាណគុម្ព...។ល។
- ដំណាក់កាលចេញផ្កា: ពេលវេលាចេញផ្កា êមុន ឬក្រោយé សណ្ឋាណគ្រាប់ êមានកន្ទុយ ឬអត់កន្ទុយé
- ដំណាក់កាលស្រូវទុំ: ទំហំគ្រាប់ êកន្ទុល ឬល្អូនé ពណ៌គ្រាប់ និងរោម





# ការប្រមូលផល និងការប្រតិបត្តិ
# ក្រោយពេលប្រមូលផល



# ការប្រមូលផល

- ការប្រមូលផលនៅពេលស្រូវទុំត្រឹមត្រូវ គឺជាការចាំបាច់ក្នុងការផលិតគ្រាប់ពូជអោយមានគុណភាពល្អ។
- ស្រូវត្រូវតែច្រូតកាត់ជាបន្ទាន់ នៅពេលដែលវាបានទុំត្រឹមត្រូវហើយ ជៀសវាងការពន្យាលពេល។
- ការពន្យាលពេលជាហេតុបណ្ដាលអោយស្រូវដួលជ្រុះរោយគ្រាប់ កណ្ដុរបំផ្លាញ ហើយជូនកាលគ្រាប់ត្រូវបានដុះពន្លកនៅនឹងកួរ ចំពោះពូជដែលគ្មានដំណេក

# ការប្រមូលផល ...ត...

- ការពន្យាលពេលបណ្តាលអោយដួលដើម ដែលធ្វើអោយទិន្នផលគ្រាប់ថយចុះ និងមានឥទ្ធិពលទៅលើគុណភាពគ្រាប់។
- ត្រូវតែធ្វើការបង្ហូរទឹកចេញ ដើម្បីអោយដីស្រែស្ងួតរឹងមុនពេលច្រូតកាត់ ដើម្បីកុំអោយគ្រាប់ត្រូវខ្ចូចខាតដោយ សារទឹក និងប្រឡាក់ភក់ក្នុងពេលច្រូតកាត់។

# ការបោកបែន

- ស្រូវដែលច្រូតកាត់ហើយត្រូវបានបោកបែនដោយដៃ។
- ការបោកបែនត្រូវជៀសវាងនូវការបោកខ្លាំងទៅលើគ្រាប់ពូជ។
- ការបោកខ្លាំងធ្វើអោយខូចខាតដល់អំប្រីយ៉ុង ជាពិសេសនៅពេលដែលគ្រាប់មានសំណើមខ្ពស់ក្នុងពេលបោកបែននេះ ហើយដែលធ្វើអោយគុណភាពគ្រាប់ត្រូវចុះអន់ថយ។
- ប្រសិនបើ ស្រូវបានច្រូតកាត់នៅពេលដែលគ្រាប់មានសំណើមខ្ពស់ខ្លាំង ត្រូវធ្វើការហាលសំងួតជាមុនសិនមុននឹងបោ



# ការហាលសំងួត

- ចូរចាំថា គ្រាប់នៅពេលទុំ និងនៅពេលច្រូត ផ្ទុកទៅដោយសំ ណើម។ ហេតុដូចនេះ គ្រាប់ពូជត្រូវតែសំងួតដើម្បីបញ្ចុះសំណើម អោយទៅដល់កម្រិតសុវត្ថិភាពមួយមុននឹងរក្សាទុក។
- ការសំងួតគ្រាប់ គឺយើងសំងួតដោយហាលថ្ងៃ បើថ្ងៃបើកល្អគឺយើងហាលចំនួន ៣ ថ្ងៃ ដោយហាលក្នុងកម្រាស់ស្តើងល្អ ហើយឧស្សាហ៍រាវីលើគ្រាប់ពូជ ដើម្បីអោយគ្រាប់ស្ងួតសព្វល្អ។
- ការហាល គួរប្រើកន្ទេល ឬថង់ប្លាស្ទិចក្រាលពីក្រោម ដោយជៀសវាងការហាល



# ការហាលសំងួត ...ត...

- ការហាលលើឥដ្ឋផ្ទាល់ ធ្វើអោយមានកំដៅខ្លាំងពេក ដែលជាហេតុបណ្តាលអោយងាប់អំប្រិយ៉ុងនៃដំណុះ។
- ប្រសិនបើហាលពូជច្រើនក្នុងពេលដំណាលគ្នា គួរតែហាលអោយឃ្លាតឆ្ងាយពីគ្នាប្រវែង ៣-៥ ម៉ែត្រ ជៀសវាងការលាយពូជ។
- អត្រាសំណើមនៃគ្រាប់ពូជដែលបានហាលហើយ មុននឹងយកទៅរក្សាទុកត្រូវអោយមានកម្រិតសំណើមក្នុងគ្រាប់មិនអោយខ្ពស់ជាង ១៤ ភាគរយ។

# ការរក្សាទុកគ្រាប់ពូជ

- គ្រាប់ពូជមុនពេលបញ្ជូនទៅរក្សាទុកក្នុងជង្រុក គួរច្រកទុកក្នុងបាវ និងមានសរសេរឈ្មោះពូជអោយបានច្បាស់លាស់។



- ការរក្សាទុកគ្រាប់ពូជ គួរជៀសវាងដាក់ផ្ទាល់នឹងឥដ្ឋ ព្រោះវាធ្វើអោយខូចគុណភាពគ្រាប់ដោយសារជម្ងឺផ្សិត និងងាយស្រួលសត្វល្អិតផ្សេងៗ បំផ្លា



# សូមអរគុណ

# ចំពោះការយកចិត្តទុកដាក់

# របស់យើងទាំងអស់គ្នា !!!



